មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI00200

# សម្ភាសន៍ជាមួយឈ្មោះ យក់ នាម ភេទប្រុស អាយុ៦៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ធ្វើស្រែ

## រស់នៅភូមិទ្រយោង ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## សម្ភាសន៍ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា

០០:៤៧:០១

២៧ទំព័រ

នាម : មុនដំបូងមកអញ្ចេះ បើកឡានមកអញ្ចេះ តែអត់ដឹងរឿងអីទេស្រាប់តែគេមកសួរខ្ញុំស្នាន តែគេមកសួរលេងធម្មតាមិនដឹងថាគេយកពត៌មានអីទេមុនដំបូងបង្អស់កាលនោះមានស្រីដែរ ជាជនក៏មានដែរជនបារាំងណាំដល់ខ្ញុំនិយាយៗទៅខ្ញុំប្រាប់ថាមានកន្លែងមានសន្តិសុខមួយនៅ ភូមិទ្រយោងមិនបានដឹងកន្លែងកាលនោះលើកនោះឯងបានគេទៅឲ្យពត៌មានមកពីនោះទៀត មកថាខ្ញុំហ្នឹងស្គាល់ តាកាន់ តាកាន់នៅប៉ៃលិន ថាអត់ទេខ្ញុំមិនដែលបាន និយាយទេរឿង តាកាន់ខ្ញុំមិនដែលបានស្គាល់ទេក៏ខ្ញុំមិនដែលបាននៅកន្លែងនេះ តាកាន់ និង យាយចែម គាត់នៅកន្លែងនេះមែនក៏ប៉ុន្តែខ្ញុំនៅភូមិចារឯណោះធ្វើម៉េចបានស្គាល់ប្រវត្តិគាត់ថាគាត់ដឹក នាំប្រជាជនអញ្ចេះៗអត់ដឹងទេ ។

ដារ៉ា : អញ្ចឹងមុនដំបូងមានស្រីជនជាតិបរទេស?

នាម : អត់ទេ ខ្មែរ ។

ដារ៉ា : ស្រីខ្មែរយើង?

នាម : បាទ!

ដារ៉ា : ហើយបរទេសប្រុស២នាក់?

នាម : បាទ!

ដារ៉ា : មកជួបដំបូង?

នាម : បាទ!

ដារ៉ា : ហើយអ៊ីក៏និយាយសំណេះសំណាលតាមធម្មតា?

នាម : បាទ!

ដារ៉ា ៖ ដល់ពេលសំណេះសំណាលអញ្ចឹងហើយគេត្រឡប់ទៅវិញ?

នាម ៖ បាទ! គេត្រលប់ទៅវិញទៅ ហើយយូឆ្នាំហើយ ។

ដារ៉ា ៖ យូឆ្នាំហើយ?

នាម ៖ បាទ! យូឆ្នាំហើយ ទើបឆ្នាំនេះបានមកពីរដងទៀត ប៉ុន្តែមកសុទ្ធតែប្លែកមុខទាំងអស់ ។

ដារ៉ា ៖ ចុះនៅក្នុងឆ្នាំ២០១១នេះ ពេលដែលមកជួបអ៊ំលើកទី២ហ្នឹងគេមកសំដៅមកផ្ទះអ៊ំតែ ម្តង ឬក៏ម៉េចអ៊ំ?

នាម ៖ លើកទី២នៅសាលាឃុំ ដល់ខ្ញុំទៅកាលនោះមេឃុំគេធ្វើបុណ្យខួបបង ខ្ញុំទៅនោះ គេទូរស័ព្ទប្រាប់មេឃុំ ហើយខ្ញុំក៏នៅនោះក៏ជួបគ្នាទៅ ។ ដល់ក្រោយមកនេះបានគេមកយកពត៌មានទៀតនេះ បានស្រីម្នាក់ហ្នឹងហើយជនជាតិ២នាក់ហ្នឹង ។

ដារ៉ា ៖ ស្រីម្នាក់ ហើយជនជាតិ២នាក់?

នាម ៖ បាទ!

ដារ៉ា ៖ ក្រោយពីដែលជួបអ៊ំនៅកន្លែងឃុំហ្នឹង?

នាម ៖ បាទ! បើនិយាយរួមទៅ ជនជាតិ២នាក់ ខ្មែរម្នាក់នៅបើកឡាន ស្រីម្នាក់អ្នកសួរខ្ញុំ បើនិយាយរួមទៅ៤នាក់ដែលមកកន្លែងនេះ បើនៅកន្លែងឃុំវាមានជនជាតិ២នាក់ ខ្មែរ៤នាក់ ខ្ញុំក៏មិនបានជាចាំដែរក្នុងតារាងនេះណាស ប៉ុន្តែគេប្រាប់ឈ្មោះខ្ញុំតែ២នាក់ទេ ។

ដារ៉ា ៖ ចុះអ៊ំ ពេលដែលនៅកន្លែងឃុំ មកដល់គេសំដៅមកអ៊ំហ្មង?

នាម ៖ បាទ! សំដៅមកខ្ញុំហ្នឹង ។

ដារ៉ា ៖ នួន ជារ័ត្ន?

នាម ៖ ជារ័ត្ន! គាត់ថាបើអ៊ំឯងមានការអី អ៊ំឯងទូរស័ព្ទទៅ ខ្ញុំមិនដែលមានទូរស័ព្ទបានអីនឹងទាក់ទង ខ្ញុំលែងមានទូរស័ព្ទកាន់ហើយ ។

ដារ៉ា ៖ ហើយដល់អញ្ចឹងទៅគេបានអញ្ជើញអ៊ំទៅកន្លែងឃុំ?

នាម ៖ បាទ!

ដារ៉ា ៖ ទៅកន្លែងឃុំហ្នឹង ពេលអ៊ំទៅដល់ឃុំភ្លាមបានជួបក្រុមហ្នឹងតែម្តង?

នាម ៖ បាទ! គេនៅចាំខ្ញុំ ។

ដារ៉ា ៖ គេចាំនៅសាលាឃុំហ្នឹងហ្មង?

នាម ៖ បាទ!

ដារ៉ា ៖ សាលាឃុំអីគេអ៊ំ?

នាម ៖ សាលាឃុំភ្នំលៀប ។

ដារ៉ា ៖ នៅហ្នឹងមានដូចថាឡានអីទេ?

នាម ៖ ឡានមក២ ។

ដារ៉ា ៖ ដល់ពេលចូលទៅដល់ គេបង្ហាញខ្លួនគេយ៉ាងម៉េចដែរអ៊ំ?

នាម ៖ អត់ទេ គេអង្គុយត្រៀមនៅតាមតុ ហើយអញ្ជើញខ្ញុំទៅអង្គុយពីមុខគេ ។

ដារ៉ា ៖ អង្គុយពីមុខ ហើយអ៊ំពេលជួបអញ្ចឹងដូចថាភិតភ័យដែរអ៊ំ?

នាម ៖ ទេ! ខ្ញុំអត់មានភិតភ័យអីទេ ព្រោះដូចថាអត់មានស្អីត្រង់ណាឲ្យប្រជាជនស្អប់ខ្ញុំកន្លែងណាអត់មានទេ ។

ដារ៉ា ៖ អត់មានទេ?

នាម ៖ បាទ! អត់មានសោះ មេឃុំនៅតែស្គាល់ គេមកមេឃុំ មេឃុំស្គាល់ថា ទេ! កាលសម័យ៣ឆ្នាំគាត់ធ្វើអីបានជាគេហៅរក បានជាគេហៅគាត់ទៅខាងតុលាការ គេស្គាល់អញ្ចឹងទៀត ។

ដារ៉ា ៖ ហើយដល់ពេលទៅដល់ទៅជួប?

នាម ៖ បាទ!

ដារ៉ា ៖ ដល់ពេលជួបទៅអ៊ំអត់មានអារម្មណ៍យ៉ាងម៉េចទេ?

នាម ៖ អត់មានអារម្មណ៍ថាយ៉ាងម៉េចទេ ព្រោះខ្ញុំមិនដែលមានអីសោះ អត់មានអារម្មណ៍ភ័យខ្លាចអីទេ គេសួរដែរ ពេលឡើងទៅដល់គេសួរថាម៉េចអ៊ំភ័យទេ ទេអត់មានភ័យអីទេ ព្រោះខ្ញុំអត់មានទោសមានអីទេ ខ្ញុំអត់មានក្បត់មានអីសោះ ខ្ញុំចាប់តាំងពីកើតមកមិនដែលបានទៅលួចមាន់អ្នកណាមួយមកស៊ីផង ។

ដារ៉ា ៖ ហើយដល់ពេលអញ្ចឹងគេចាប់ផ្ដើមសួរអ៊ំហ្មង?

នាម ៖ បាទ! ចាប់ផ្ដើមសួរ ។

ដារ៉ា ៖ ពេលសួរអ៊ំហ្នឹង គេមានឲ្យអ៊ំស្បថទេ?

នាម ៖ បាទ! គេឲ្យស្បថឲ្យនិយាយការពិតប៉ុណ្ណោះឯង ។

ដារ៉ា ៖ តែប៉ុណ្ណឹងទេ?

នាម ៖ បាទ!

ដារ៉ា ៖ ហើយចាប់ផ្ដើមសួរនាំ?

នាម ៖ បាទ! គេចាប់ផ្ដើមសួរ ។

ដារ៉ា ៖ សួរនាំហ្នឹង អ៊ំរ៉ាយរ៉ាប់ទាំងអស់អញ្ចឹងទៅ?

នាម ៖ បាទ! សួរសំនួរមួយខ្ញុំឆ្លើយៗ ត្រង់ណាដែលខ្ញុំដឹងខ្ញុំប្រាប់ថាខ្ញុំដឹង ត្រង់ណាមិនដឹងខ្ញុំប្រាប់ថាមិនដឹង ។

ដារ៉ា ៖ ហើយដល់ពេលសួរហើយអញ្ចឹង គេបានឲ្យក្រដាសមកអ៊ំ ហើយផ្តិតមេដៃទៅ?

នាម ៖ បាទ! ផ្តិតមេដៃ ។

ដារ៉ា ៖ ហើយផ្តិតមេដៃហ្នឹងគេបានអានអីឲ្យពូស្តាប់ទេ?

នាម ៖ គេអានឲ្យខ្ញុំស្តាប់ទាំងអស់ ហើយបើយើងមានយល់ទាស់កន្លែងណាមួយ គេនិយាយថាអញ្ចឹង គេថាបើអ៊ីឯងមានយល់ទាស់កន្លែងណាមួយអ៊ីឯងប្រាប់ខ្ញុំ ដល់ពេលនិយាយទៅវាទៅតាមដំណើរដែលខ្ញុំនិយាយហ្នឹង ។

ដារ៉ា ៖ វាស្របទាំងអស់ហើយបានអ៊ំផ្តិតមេដៃ?

នាម ៖ បាទ!

ដារ៉ា ៖ គេសួរពេលហ្នឹងមានថតជាសម្លេងដែរអត់?

នាម ៖ ទេ! ប្រហែលជាថតតាមមើលទៅ ព្រោះឃើញ តែខ្ញុំអ្នកស្រុកស្រែដែលទៅឃើញប្រដាប់ប្រដាដូចថា សម័យដែលគេធ្វើម៉េចៗខ្ញុំមិនដែលដឹងទេ ។

ដារ៉ា ៖ មានគេដាក់ថតអញ្ចឹងដែរអ៊ំ?

នាម ៖ បាទ! ប៉ុន្តែអានេះរាងខ្មៅ ។

ដារ៉ា ៖ តែមានដាក់ថតអញ្ចឹងដែរ?

នាម ៖ បាទ! ដាក់អញ្ចឹងឯង ។

ដារ៉ា ៖ ហើយមានថតរូបអ៊ំដែរ?

នាម ៖ ទេ! អត់មានទេ ។

ដារ៉ា ៖ អត់មានថតរូបអ៊ំទេ?

នាម ៖ អត់មានឃើញថតទេ បើគេថតយ៉ាងណាមិនដឹងទេណា៎ ប៉ុន្តែអត់មានឃើញមានថតអីទេ ។

ដារ៉ា ៖ មានថតកាមេរ៉ាអញ្ចឹងទេ?

នាម ៖ អត់ទេ ។

ដារ៉ា ៖ តែពេលសួរនាំហ្នឹងគេមានវ៉ៃកុំព្យូទ័រ?

នាម ៖ បាទ!

ដារ៉ា ៖ ហើយវ៉ៃហើយ គេព្រីនឲ្យអ៊ំចុះហត្ថលេខា អានហើយចុះហត្ថលេខា?

នាម ៖ អានរួចបានចុះហត្ថលេខា ហើយបានគេសួរខ្ញុំថា អ្នកមកក្រោយសួរខ្ញុំថា អ៊ំ! បើគេយកទៅភ្នំពេញទៅទេ? ខ្ញុំថាទៅអត់រួចទេ ខ្ញុំមិនដែលជិះឡានផង មិនដឹងជិះម៉េចទេ ខ្ញុំមិនទៅទេ ។

ដារ៉ា ៖ ពេលដែលសួរនៅឃុំហើយមែនអ៊ំ?

នាម ៖ បាទ! មកសួរនៅនេះ អ្នកក្រោយ ។

ដារ៉ា ៖ ហ្អស! អ្នកក្រោយ អ្នកក្រោយថាមានបរទេសមក ហើយមានស្រីបកប្រែហ្នឹង?

នាម ៖ បាទ! ខ្ញុំមិនទៅទេ ។

ដារ៉ា ៖ អញ្ចឹងពេល ខ្ញុំចង់បញ្ជាក់ម្តងទៀត ពេលអ្នកដែលគេមកពីភ្នំពេញ ខាងតុលាការមកហ្នឹង គឺមកសំដៅរកអ៊ំហ្នឹង?

នាម ៖ បាទ!

ដារ៉ា ៖ សំដៅរកឈ្មោះអ៊ំហ្នឹង?

នាម ៖ សំដៅមកឈ្មោះខ្ញុំតែម្តង ឡើងមេឃុំឆ្លល់ ។

ដារ៉ា ៖ ចុះពេលដែលតុលាការមកដល់ ហើយអញ្ជើញអ៊ំទៅដល់កន្លែងសាលាឃុំ អ៊ំមានបានសួរសំនួរទៅតុលាការវិញ ថាហេតុអីបានជាស្គាល់ខ្ញុំ?

នាម ៖ ខ្ញុំអត់បានសួរទេ ។

ដារ៉ា ៖ អត់មានបានសួរទេ?

នាម ៖ អត់បានសួរទេ គេដាក់ឈ្មោះមកចំតែម្តង មិនបានសាកសួរអីផង ។

ប្រពន្ធ ៖ គេមកហ្នឹង គេទូរស័ព្ទមកឃុំមុន គេសួរឈ្មោះតានេះស្គាល់អត់ ហើយទៅណា ហើយឃុំថាតានៅកន្លែងបុណ្យ ហើយក៏ហៅទៅជួបគ្នា សួរថាគេមករកអី ហើយថាតុលាការគេមករកមានរឿងហេតុអី ហើយគាត់ថាគ្មានរឿងអីទេ ខ្ញុំមិនដែលមានរឿងអីទេ ។

ដានី ៖ អញ្ចឹងអ៊ំខ្ញុំចង់សួរអ៊ំបន្តិចទាក់ទងពីជីវិតផ្ទាល់ខ្លួនរបស់អ៊ំ អញ្ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះពេញអ៊ំ តើអ៊ំឈ្មោះអីដែរ?

នាម ៖ ហេតុអីចាំបាច់រកឈ្មោះខ្ញុំ?

ដានី ៖ ចង់ដឹងឈ្មោះអ៊ំ ឲ្យអ៊ំនិយាយប្រាប់ឈ្មោះ ។

ដារ៉ា ៖ គ្រាន់តែឲ្យអ៊ំនិយាយហើយថតសម្លេង ។

នាម ៖ ដែលមករកហ្នឹង បានឈ្មោះពីណាបានដឹងឈ្មោះខ្ញុំ ប្អូនឯងដឹងពីណា ខ្ញុំសួរថាប្អូនឯងដឹងពីណាដែលថាខ្ញុំឈ្មោះនាម?

ដានី : ខ្ញុំដឹងតាម ដូចថាពួកពូប្រធានភូមិពីខាងព្រះនេត្រព្រះ អញ្ចឹងទៅក៏មករកជួបអ៊ំទៅ អញ្ចឹងខ្ញុំចង់ដឹងឈ្មោះពេញអ៊ំ?

នាម : ខ្ញុំបើនិយាយពីខាងព្រះនេត្រព្រះដូចមិនដែលមានទំនាក់ទំនងអីទេ មិនដែលមានស្គាល់ទំនាក់ទំនងខាងព្រះនេត្រព្រះ មិនដែលមានស្គាល់អ្នកណាម្នាក់ទេ បើថានិយាយពីខាងនោះមានស្គាល់ខ្ញុំដូចមិនមាន បើថាខ្មែររយៈប្អូនឯងដែលមកស្គាល់ខ្ញុំនេះស្គាល់ត្រឹមណាមក?

ដារ៉ា : ខ្ញុំស្គាល់ពូហ៊ុយ ។

នាម : បាទ?

ដារ៉ា : ខ្ញុំស្គាល់ពូហុង ហ៊ុយ ។

ដានី : ហុង ហ៊ុយ មេឃុំព្រះនេត្រព្រះ ។

ដារ៉ា : ហុង ហ៊ុយ ហ្នឹងគាត់មេឃុំនៅព្រះនេត្រព្រះ ហើយគាត់ទំនាក់ទំនងមកមេឃុំនៅភ្នំលៀបនេះ ហើយបានគាត់ដឹងឈ្មោះពូ ហើយបានគាត់ប្រាប់ឈ្មោះពូទៅខ្ញុំ ហើយបានខ្ញុំមករកពូ ខ្ញុំដឹង ថាមានខាងមិនមែនដឹងទេដូចថាពូធ្លាប់ ដូចថាអាចដឹងរឿងក្រៅពីភ្នំទ្រយោងអញ្ចឹងណា៎ ហើយថ្មីៗហ្នឹងខាងតុលាការគេចេញពត៌មានទាក់ទងនឹងរឿងការស៊ើបអង្កេតនៅភ្នំទ្រយោង មន្ទីរសន្តិសុខភ្នំទ្រយោងណាអ៊ំ ហើយដល់អញ្ចឹងទៅពួកខ្ញុំក៏ចង់ដឹងថាតើអ្នកណាខ្លះដែលអាច ដឹងរឿងរ៉ាវពីរឿងនៅភ្នំទ្រយោងនៅអីអញ្ចឹងណាអ៊ំ អញ្ចឹងខ្ញុំស្រាវជ្រាវមកតាមពូ ហ៊ុយ តាមអីហ្នឹង ។

នាម : ពូហ៊ុយ ហ្នឹងខ្ញុំមិនដែលស្គាល់ទេ ។

ដារ៉ា : អត់ដែលស្គាល់ តែគាត់ទាក់ទងមកខាងឃុំភ្នំលៀប គាត់ឃុំដូចគ្នា ដល់អញ្ចឹងគាត់មានទំនាក់ទំនងទៅ ។

នាម : នឹកឃើញថាស្គាល់ក្រុមនេះបានដឹងឈ្មោះខ្ញុំ ។

ដារ៉ា : អត់ទេ!

នាម : បើមិនក្រុមនេះមិនស្គាល់ឈ្មោះខ្ញុំទេ ។

ដារ៉ា : អញ្ចឹងបានសួរឈ្មោះអ៊ំម្តងទៀត ដើម្បីឲ្យបានជាប់នៅក្នុងសម្លេង ។

ដានី : អញ្ចឹងសុំអ៊ំអាចជម្រាបឈ្មោះអ៊ំម្តងទៀត អ៊ំឈ្មោះពេញឈ្មោះអីដែរ?

នាម : ឈ្មោះ នាម ។

ដានី : ត្រកូលអីដែរ?

នាម ៖ ឈ្មោះ យក់ ។

ដានី ៖ យក់ នាម?

នាម ៖ បាទ!

ដានី ៖ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

នាម ៖ អាយុ៦៥ហើយ ។

ដានី ៖ ចុះប្រពន្ធអ៊ំគាត់ឈ្មោះអីដែរ?

នាម ៖ ឈ្មោះ ភឿង ។

ដានី ៖ ចុះត្រកូលគាត់ឈ្មោះអី?

នាម ៖ ឈ្មោះ លាក់ ភឿង ។

ដានី ៖ គាត់អាយុប៉ុន្មានដែរអ៊ំ?

នាម ៖ គាត់អាយុ៦២ ។

ដានី ៖ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

នាម ៖ មានកូន១ ។

ដានី ៖ ស្រីឬប្រុស?

នាម ៖ ស្រី ។

ដានី ៖ គាត់ឈ្មោះអីដែរ?

នាម ៖ ឈ្មោះ ស៊ីណា ។

ដានី ៖ ចុះអ៊ំ ស្រុកកំណើតកើតជាអ៊ំនៅណាដែរ?

នាម ៖ នៅនេះឯង ។

ដានី ៖ នៅភូមិអីគេ?

នាម ៖ ភូមិទ្រយោង ។

ដានី ៖ ឃុំអីនៅហ្នឹង?

នាម ៖ ឃុំភ្នំលៀប ។

ដានី ៖ ស្រុក?

នាម ៖ ស្រុកព្រះនេត្រព្រះ ។

ដានី ៖ ខេត្តបន្ទាយមានជ័យ ។ ចុះសព្វថ្ងៃអ៊ំរស់នៅក្នុងភូមិឃុំអីដែរ?

នាម ៖ សព្វថ្ងៃហ្នឹងនៅកន្លែងនេះដដែល ។

ដានី ៖ នៅកន្លែងភូមិអីដែរ?

នាម ៖ ភូមិទ្រយោងហ្នឹងឯង ។

ដានី ៖ នៅភូមិទ្រយោងដដែល?

នាម ៖ បាទ! នៅភូមិដដែល ឃុំដដែល ។

ដានី ៖ ចុះអ៊ំ ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

នាម ៖ ឪពុកខ្ញុំគាត់ឈ្មោះ យក់ ញ៉ឹប ។

ដានី ៖ សព្វថ្ងៃគាត់នៅរស់ទេ?

នាម ៖ គាត់ខូចអស់ហើយ គាត់ស្លាប់អស់ហើយទាំងម៉ែទាំងឪ ។

ដានី ៖ គាត់ខូចតាំងពីអន្កាល់?

នាម ៖ តាំងពីឆ្នាំ៧៦ ។

ដានី ៖ គាត់ខូចដោយសារមូលហេតុអី?

នាម ៖ គាត់គ្រុន ហើយអត់មានពេទ្យ អត់មានថ្នាំសន្លូវលេប ។

ដានី ៖ គាត់ឈ្មោះ យក់ ញ៉ឹប?

នាម ៖ បាទ! គាត់ស្លាប់សម័យនោះអត់មានថ្នាំទេ សម័យ៣ឆ្នាំវាចូលកាន់កាប់នៅឆ្នាំ៧៥ ។

ដានី ៖ ចុះម្តាយ?

នាម ៖ ម្តាយឈ្មោះ ពេជ្រ រឿន គាត់ស្លាប់ហើយ ។

ដានី ៖ ពេជ្រ រឿន គាត់ស្លាប់ពីអន្កាល់ដែរ?

នាម ៖ គាត់ស្លាប់កាលឆ្នាំ២០០០ ។

ដានី ៖ អញ្ចឹងទើបតែស្លាប់ឥឡូវៗនេះដែរ?

នាម ៖ បាទ! ឥឡូវឆ្នាំ២០១១ហើយ ។

ដានី ៖ ចុះអ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

នាម ៖ បងប្អូនបង្កើត៣នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

នាម ៖ ស្រី១ ប្រុស២ ។

ដានី ៖ ចុះអ៊ំកូនទីប៉ុន្មាន?

នាម ៖ ខ្ញុំកូនទី៣ ។

ដានី ៖ អញ្ចឹងពៅគេ?

នាម  :  បាទ!

ដានី  :  ក្នុងចំណោមបងប្អូន៣នាក់ហ្នឹងអ៊ំពៅគេ?

នាម  :  បាទ!

ដានី  :  ចុះអ៊ំ  កាលពីក្មេងៗអ៊ំរៀនសូត្រដល់ណាដែរ?

នាម  :  ខ្ញុំរៀន  បើនិយាយពីសង្គមចាស់ថ្នាក់ទី៣ ។

ដានី  :  រៀនថ្នាក់ទី៣?

នាម  :  ហ្នឹងកាលសង្គមចាស់  បើយើងរាប់ទៅតាមគេ  ដូចខ្ញុំថាពីសង្គមចាស់ថ្នាក់ទី១២,១១,១០

ដានី  :  អ៊ំរៀននៅសាលាណា?

នាម  :  សាលាភ្នំលៀប ។

ដានី  :  កាលហ្នឹងនៅសាលាភ្នំលៀបមានដល់ថ្នាក់ទី៣ដែរ?

នាម  :  ទី៣យើងពីសង្គមចាស់មាន  បើគិតទៅវាមានទី៩,១០ទេបើយើងរាប់ពីចាស់  ពីសម័យនោះអត់មានរាប់ទី១,២ដូចសព្វថ្ងៃនេះទេ ។

ដានី  :  អញ្ចឹងអ៊ំរៀនរហូតដល់...?

នាម  :  រៀនបាន៣ថ្នាក់ទេ ។

ដានី  :  អ៊ំរៀនបាន៣ថ្នាក់?

នាម  :  បាទ!

ដារ៉ា  :  រៀនបាន៣ថ្នាក់  មានតែដល់ថ្នាក់ទី១០?

ដានី  :  ថ្នាក់ទី១០ពីដើម?

នាម  :  បាទ!

ដានី  :  ចុះអ៊ំឈប់រៀនឆ្នាំណា?

នាម  :  ខ្ញុំអត់ចាំទេ ។

ដានី  :  បានន័យថាឈប់រៀនក្នុងសម័យលន់  នល់  ឬក៏តាំងពីសម័យសង្គមរាស្ត្រនិយម?

នាម  :  សង្គមរាស្ត្រនិយម ។

ដានី  :  ចុះពេលឈប់រៀនហើយអ៊ំធ្វើអីទៀតទៅ?

នាម  :  អត់មានធ្វើអីទេ  ធ្វើស្រែ ។

ដានី  :  នៅស្រែនៅណាទៅ?

នាម  :  នៅកន្លែងនេះឯង  នៅក្នុងភូមិនេះ ។

ដានី : ធ្វើស្រែជាមួយឪពុកម្ដាយ?

នាម : បាទ!

ដានី : អ៊ំធ្វើស្រែរហូតដល់ពេលណាទៅបានអ៊ំមានគ្រួសារ?

នាម : អាយុ ធ្វើស្រែមកចង់ដល់អាយុ២០ អាយុ២០បានមានគ្រួសារ។

ដារ៉ា : ឆ្នាំណាទៅបានអ៊ំរៀបចំគ្រួសារ?

នាម : មិនចាំឆ្នាំទេ។

ដារ៉ា : តែក្នុងរបបលន់ នល់?

នាម : ទេ...

ដានី : សង្គមរាស្ត្រនិយម?

នាម : បាទ!

ដានី : ចុះអ៊ំរៀបគ្រួសារហើយអ៊ំទៅនៅណាទៅ?

នាម : នៅកន្លែងនេះ។

ដានី : នៅភូមិហ្នឹងដដែល?

នាម : បាទ!

ដានី : ចុះអ៊ំស្រីគាត់អ្នកស្រុកភូមិនេះដែរ?

នាម : គាត់អ្នកស្រុកភូមិនេះដែរ។

ដានី : ពេលអ៊ំរៀបគ្រួសារហើយ អ៊ំនៅជាមួយឪពុកម្ដាយទៀតឬក៏បែកផ្ទះ?

នាម : បានមួយឆ្នាំបានបែក។

ដានី : នៅជាមួយឪពុកម្ដាយមួយឆ្នាំហើយបានបែក?

នាម : បាទ!

ដានី : ធ្វើអីទៅដល់ពេលបែកផ្ទះ?

នាម : ធ្វើតែស្រែធម្មតា។

ដានី : ធ្វើស្រែរហូតដល់ពេលណាទៅ?

នាម : រហូតមកដល់សព្វថ្ងៃ។

ដានី : ប៉ុន្តែពីសម័យហ្នឹងដូចថាយើងធ្វើកាលពីសង្គមរហូតមកយើងមិនមានសង្គ្រាម អញ្ចឹងអ៊ំធ្វើស្រែរហូតដល់ពេលណាទៅបានអ៊ំឈប់?

នាម : សម័យហ្នឹងអត់មានបានឈប់ទេ សម័យ៣ឆ្នាំក៏ខ្ញុំនៅតែធ្វើស្រែ។

ដានី :　អញ្ចឹង?

នាម :　បាទ! ធ្វើស្រែរហូត ។

ដានី :　ចុះអ៊ំ អញ្ចឹងដល់ពេលរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ឆ្នាំ១៩៧០ កាលហ្នឹងអ៊ំនៅក្នុងស្រុកភូមិហ្នឹងធ្វើស្រែដែរ ឬក៏មានអី?

នាម :　បាទ! ធ្វើស្រែដដែល ធ្វើតែស្រែអញ្ចឹងឯង ។

ដានី :　ចុះដល់ពេលបែកឆ្នាំ៧៥?

នាម :　បែកឆ្នាំ៧៥ក៏នៅធ្វើតែស្រែ ។

ដានី :　បែកឆ្នាំ៧៥បានន័យថា ដូចថាស្ថានភាពអីនៅក្នុងស្រុកភូមិហ្នឹងយ៉ាងម៉េចទៅ?

នាម :　ស្ថានភាពនៅក្នុងស្រុកភូមិយើងកាលសម័យសង្គ្រាមគេចូលមកនោះ គេអត់មានឲ្យនៅក្នុងភូមិដដែលទេ គេជម្លៀសចេញ ។

ដានី :　គេជម្លៀសចេញ?

នាម :　បាទ! គេជម្លៀសចេញពីភូមិ ។

ដានី :　ឆ្នាំណាដែលគេជម្លៀសចេញពីភូមិហ្នឹង?

នាម :　ឆ្នាំ៧៥ ។

ដានី :　ឆ្នាំ៧៥ ខែណាដែរ?

ដារ៉ា :　៧៥ ដែលខ្មែរក្រហមចូលមកហ្នឹង?

នាម :　បាទ!

ដានី :　ខែប៉ុន្មានដែរ ដូចថាយើងបែកភ្នំពេញនៅថ្ងៃ១៧មេសា ឆ្នាំ៧៥ អញ្ចឹងនៅស្រុកភូមិរបស់អ៊ំហ្នឹងពេលណាបានគេជម្លៀសអ៊ំចេញពីស្រុកពីភូមិ?

នាម :　កាលនោះ ខ្ញុំស្មាន តែខ្ញុំមិនច្បាស់ទេ ប្រហែលជាចូលមកកាន់កាប់បានកន្លះខែប៉ុណ្ណោះឯងបានជម្លៀសចេញ ។

ដានី :　គេជម្លៀសអ្នកស្រុកអ្នកភូមិចេញទាំងអស់ ឬក៏គេ?

នាម :　គេជម្លៀសចេញទាំងអស់ ។

ដានី :　ចេញឲ្យទៅនៅណាទៅអ៊ំកាលនោះ?

នាម :　ចេញទៅនៅមុនដំបូងនៅបត់ត្រង់ ។

ដានី :　នៅឯណា នៅបត់ត្រង់?

នាម :　បាទ! បត់ត្រង់ ឡោទដែលប្អូនឯងទៅមិញហ្នឹង?

ដានី : បត់ត្រង់ ឡោទេ ។

ដារ៉ា : អត់ឲ្យនៅក្នុងភូមិទេ?

នាម : អត់ឲ្យនៅទេកាលមុនដំបូង លើកទី១គេចេញទៅនៅបត់ត្រង់ហ្នឹង ប៉ុន្តែកាលនោះដែលមាន នៅគោនៅរទេះគេមិនទាន់ដកទេ ។

ដារ៉ា : ការជម្លៀសអញ្ចឹង ខ្មែរក្រហមមានប្រាប់ហេតុផលអីដែរទេ?

នាម : អត់ទេ អត់មានប្រាប់ហេតុផលទេ ។

ដារ៉ា : ឲ្យចេញតែម្តង?

នាម : គេថាឲ្យចេញពីភូមិ ដល់កាលហ្នឹងនៅគោរទេះគេមិនទាន់ដកទេ ហើយខ្ញុំក៏លើកអន្ទរលើកអី ទៅប្រមូលកូនចៅចេញទៅដល់បាន៤,៥ថ្ងៃគេឲ្យចូលទៅក្នុងភូមិវិញ ។ ដល់ពេលមកបាន ៤,៥ថ្ងៃគេឲ្យចេញទៀត ចេញ៣ដងឲ្យចេញតែខ្លួនហ្នឹង អត់មានឲ្យកាន់អីទៅទេ ម៉ោង៩ ល្ងាច ប្រហែលជាខែប៉ុន្មានទេខ្ញុំមិនបានចាំ ។

ដានី : ចុះមូលហេតុអីបានជាគេឲ្យយើងចេញចូលៗអញ្ចឹង ដូចថាម្តងជម្លៀសឲ្យទៅនៅនេះ?

នាម : អត់ដឹងមូលហេតុ ព្រោះកងយោធាកាលសម័យនោះគេយោធា ។

ដានី : យោធា?

នាម : បាទ! គេកងយោធា គេបោសសម្អាតក្នុងភូមិ គេរកខ្មាំងរកអីនៅក្នុងភូមិ គេចេះតែថាៗ ទៅ ។

ដានី : កាលហ្នឹងខាងណា អ៊ំស្គាល់ឈ្មោះអ្នកដែលគ្រប់គ្រងទេ?

នាម : អត់ស្គាល់ទេ ។

ដានី : អ្នកគ្រប់គ្រងក្នុងភូមិ គេខាងយោធាដែរ?

នាម : អត់មានស្គាល់ទេ គេមិនឲ្យស្គាល់ទេ ។

ដានី : ចុះដំបូងអ៊ំជម្លៀសទៅខាងបត់ត្រង់ ទៅខាងឡោទេ ដល់ពេលក្រោយទៀតជម្លៀសទៅ ណាវិញ?

នាម : ៣ដងទៅឡោទេ ដល់ម្តងក្រោយទៀត អ៊ំៗ ម៉ោង៩ល្ងាច អ៊ំៗចេញពីភូមិទៅតែ២ ម៉ោងទេអ៊ំចេញទៅវាលនេះ ។

ដានី : ទៅវាលណាទៅ?

នាម : វាលយើងនេះឯង វាលខាងក្រោយផ្ទះខ្ញុំនេះ ។

ដានី : ខាងក្រោយផ្ទះហ្នឹងគេហៅអី?

នាម ៖ គេហៅវាលអូរលៀប ។

ដានី ៖ ទៅទាំងអស់គ្នា?

នាម ៖ ចេញទាំងអស់ ម៉ាភូមិគឺចេញទាំងអស់ ក្នុងភូមិនេះចេញទាំងអស់ ចេញតាំងពីឃុំ ក្នុងម៉ាឃុំនេះចេញទាំងអស់ ។

ដានី ៖ គេឲ្យចេញហ្នឹងយើងទៅនៅកន្លែងវាល នៅអូរលៀបហ្នឹងមានផ្ទះមានអីស្នាក់នៅដែរ?

នាម ៖ អត់ទេៗ ទៅអត់មានជាប់អីទេទៅតែខ្លួន ។

ដានី ៖ ចុះយើងស្នាក់នៅយ៉ាងម៉េចទៅបើអត់មានផ្ទះ?

នាម ៖ អត់ទេឲ្យចេញទៅតែខ្លួន ចុះបើយោធាគេសុទ្ធតែកាំភ្លើង ចេញៗ ហើយអីចឹងយើងមិនខ្លាចគេម៉េចបើកាំភ្លើង ។ ដល់ចេញទៅដល់ពាក់កណ្ដាលផ្លូវទៅអូរលៀប ម៉ែ! កំបោរបានភ្ញាក់ខ្លួន ។ ទៅដល់អូរលៀបថ្ងៃលិចល្ងឹតឈឹងបាត់ ក្បែរកំបោរវាដើរកៀងអត់ឲ្យយើងបែកគ្នាអត់ឲ្យយើងចូលទៅភូមិវិញទេ ដើរកៀងរហូតដល់កំបោរ ។

ដានី ៖ ដល់ភូមិកំបោរហ្អី?

នាម ៖ បាទ!

ដានី ៖ ហើយមកដល់ភូមិកំបោរយ៉ាងម៉េចទៀតទៅ?

នាម ៖ អត់មានឲ្យនៅក្នុងភូមិទេ ដល់ពេលភ្លៀងរងាយ៉ាងម៉េចក៏នៅកណ្ដាលដុបទៅ ។

ដានី ៖ នៅកណ្ដាលវាល?

នាម ៖ បាទ!

ដានី ៖ អត់មានផ្ទះអីស្នាក់នៅទេ?

នាម ៖ អត់មានទេ ហួស!វេទនាណាស់ ។

ដានី ៖ ចុះយើងសំរាន្តអីយ៉ាងម៉េចទៅ?

នាម ៖ ធ្វើម៉េច ចង់ស្រួលវាចង់ហើយបើយើងខ្លាចគេនោះគេថាយ៉ាងម៉េចក៏ចឹងទៅ កុំតែគេវ៉ៃចោលសំណាងហើយ ។

ដានី ៖ ចុះយោធាដែលអ្នកបញ្ជាឲ្យយើងជម្លៀសចេញហ្នឹងយោធាពីណាមក?

នាម ៖ ទេមិនដឹងទេ ។

ដានី ៖ មិនមែនអ្នកនៅក្នុងភូមិយើងទេ?

នាម ៖ ទេ មិនមែនទេ អត់មានទេ ។

ដានី ៖ ច្រើនដែរយោធានៅក្នុងភូមិដែលជម្លៀសចេញហ្នឹង?

នាម ៖ ទេ យោធាប្រហែលជាបួនដប់នាក់តែវាកៀងយើងឲ្យចេញៗពីភូមិ វាប្រាប់ថាឲ្យចេញៗ ដល់ពេលយើងចេញឆ្ងាយពីភូមិហើយវាត្រៀមខ្សែត្រៀមមិនឲ្យយើងចេញ បែកគ្នាទៅនៅ ជុំគ្នាទៅ ។

ដានី ៖ ហើយចុះអ៊ីទៅដល់ភូមិកំពោរហើយយ៉ាងម៉េចទៀតទៅ?

នាម ៖ ដេកអត់បាយ ។

ដានី ៖ អត់បាយ?

នាម ៖ បាទ!

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

នាម ៖ មានអី!

ដារ៉ា ៖ កាលនោះអ៊ីមានកូនហើយនៅ មានកូនចៅឬនៅ?

នាម ៖ ខ្ញុំមានកូនមួយ ។

ដារ៉ា ៖ កូនមួយហ្នឹងស្រីឬប្រុស?

នាម ៖ ស្រី ។

ដារ៉ា ៖ ស្រីដែរ?

នាម ៖ បាទ! ទៅហ្នឹងក៏ យាយ គាត់ដាក់កន្ទេងទៅមួយពរកូនទៅ ហើយខ្ញុំគ្រុន ។ សម័យនោះ ប្អូនសែង ប្អូនពីរនាក់ ប្អូនថ្លៃម្នាក់ប្អូនបង្កើតម្នាក់សែងរហូតដល់សំព័រនោះក៏ភ្លៀងធ្លាក់ខ្លាំងទៅអត់រួចក៏ នៅនោះហើយ ។

ដានី ៖ ទៅដល់ណា?

នាម ៖ ភ្នំសំព័រ!

ដានី ៖ ភ្នំសំព័រ?

នាម ៖ បាទ!ជិតកំពោរដែរ ដល់ព្រឹកឡើងបានទៅកំពោរទៀត ។

ដានី ៖ ព្រលឹមឡើងទៅកំពោរ?

នាម ៖ បាទ!ពួកវាក៏មានអង្រឹងវាក៏ស្រួលវា បើយើងអត់ទៅតែដៃទទេ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅពេលទៅដល់កំពោរព្រលប់ៗ?

នាម ៖ ទៅដល់កំពោរក៏ឲ្យយើងនៅតាមដុបតាមព្រៃ អត់មានរោងអត់មានក្រសារអីទេ ។

ដានី ៖ យើងធ្វើផ្ទះធ្វើអីនៅខ្លួនឯងឬមួយយ៉ាងម៉េច គេមានផ្ទះឲ្យយើង?

នាម ៖ អត់មានទេ រោងធ្វើខ្លួនឯងកាប់ស្បូវកាប់អីទៅ ដេកនឹងដី ។

ដានី : នៅជួបជុំគ្នាដូចថាគ្រួសារយើងនៅជុំគ្នាអីចឹងឬយ៉ាងម៉េច ធ្វើរោងធ្វើអីនៅទៅ?

នាម : បាទ!

ដានី : ហើយគេឲ្យធ្វើអីទៅ?

នាម : ទេ!គេអត់ទាន់ឲ្យធ្វើអីទេបើរដូវមិនទាន់ដល់រដូវភ្ជួរណាស ។

ប្រពន្ធ : កាលយើងទៅគេមិនឲ្យមានចានមានឆ្នាំង ដេក ចាក់ស្លឹកត្នោតបបរដាក់ ។

នាម : ចាក់នឹងស្លឹកត្នោតប៉ុណ្ណោះទៅដាក់ បបរ ។ បបរគេចែកមកគេចែកអង្ករមកគេឲ្យអង្ករសុំរ៉ូប មកដល់ឲ្យបបរអត់ឲ្យដាំបាយទេ ហើយដាក់ចាក់នឹងស្លុកធ្វើម៉េចនឹងជាប់ទឹកអូនឯងពិចារណាមើល អូនឯងស្គាល់ស្លុកទេ?

ដារ៉ា : បាទ!ស្លុកដាក់បាយដំណើប ។

នាម : បាទ! ដាក់បបរណាស អត់មាន ហើយស្លាបព្រាក៏ស្លឹកត្នោតដែរទំរាំបានគេចែកឲ្យបានដោះស្រាយ វេទនាណាស់សម័យនោះ ។

ដានី : គេចែកបបរ តែយើងអត់ទាន់ទៅធ្វើការទេ?

នាម : នៅ គេចែកអង្ករឲ្យដាំ ។

ដានី : រយៈពេលប៉ុន្មានទៅ?

នាម : ដាំបាយអត់ឆ្អែត ម្លោះហើយដាំបបរចែកគ្នា ។

ដានី : គេចែកឲ្យយើងទៅស្នាក់នៅរយៈពេលប៉ុន្មានទៅបានយើង...

នាម : ខ្ញុំវាមិនចាំពីរឿងពេលវេលាទេ មិនចាំថាពីស្មើណោះស្មើណោះអត់ចាំទេ ។

ដានី : ហើយយ៉ាងម៉េចទៀតទៅអឺយើងទៅនៅគេចែកតែបបរដាក់ស្លុកដាក់អីគេឲ្យយើងដល់ពេលក្រោយទៀតគេមានបែងចែកការងារឲ្យយើងយ៉ាងម៉េចទៀតទៅ?

នាម : ក្រោយមកមិនទាន់ដឹងបានធ្វើអីទេ មិនទាន់បានធ្វើអីទេ ។

ដានី : ដល់រយៈពេលប៉ុន្មានទៅបានគេឲ្យធ្វើការងារ?

នាម : យូរ ខ្ញុំវាមិនចាំ ។

ដានី : ពេលអឺជម្លៀសទៅខែប្រាំងឬខែវស្សា?

នាម : ខែប្រាំង ។

ដានី : ដល់ពេលណាទៅបានគេចាប់ផ្ដើមបែកចែកការងារ?

នាម : ដល់ខែវស្សា ខែខ្មែរណាស!

ដានី : ខែវស្សា?

នាម ៖ បាទ!ខែខ្មែរយើងខែវស្សា ។ ខែវស្សាបានគេរកគោរកអីឲ្យរួចទៅចែក ប៉ុន្តែអត់បានចែកបាននៅឯណោះទេ ដល់គេចែកគោចែកគោចែកអីឲ្យភ្ជួររាស់បានគេដេញឲ្យផ្លាស់មកនៅស្រម៉ោចនិងនៅបត់ត្រង់អត់បានឲ្យនៅកំបោររនោះទេ ។ ដល់ពេលនោះដល់ពេលគេចែកហើយណាស ដល់គេចែកគោអីឲ្យប្រើឲ្យមកនៅអីណោះ ។

ដានី ៖ ចុះអ៊ីមកនៅឯណា?

នាម ៖ មកនៅត្រឡោក ។

ដានី ៖ នៅត្រឡោក?

នាម ៖ បាទ!

ដានី ៖ ត្រឡោកនៅឯណាទៅ?

នាម ៖ ត្រឡោកនៅខាងនោះ ។

ដានី ៖ ត្រឡោកហ្នឹងនៅជិតកំបោរដែរ?

នាម ៖ បាទ!

ដានី ៖ អីចឹងគេចែកគោចែកអីឲ្យ ចែកជាគ្រួសារឬចែកនៅក្នុងសហករណ៍?

នាម ៖ ចែកធ្វើរួម ។

ដានី ៖ ចែកធ្វើរួម?

នាម ៖ បាទ!

ដានី ៖ ចុះអ៊ីមានគោ ចុះអ៊ីស្រី?

នាម ៖ អ៊ីស្រីទៅដកសំណាបហើយក្រង់ស្បូវក្រង់អី ។

ដានី ៖ ចុះក្រោយពីអ៊ីគេចែកគោអីឲ្យអ៊ីទៅនៅត្រឡោកហ្នឹង អ៊ីភ្ជួរ ហើយអ៊ីទៅដកសំណាប ហើយចុះក្រៅពីភ្ជួរក្រៅពីដកសំណាបគេឲ្យធ្វើអីទៀតទៅ?

នាម ៖ ទេ ខ្ញុំអត់មានធ្វើអីទៀតទេមានតែភ្ជួរ ភ្ជួរទាំងប្រាំងទាំងវស្សា ។

ដានី ៖ ខែប្រាំងក៏ភ្ជួរខែវស្សាក៏ភ្ជួរ?

នាម ៖ បាទ!

ប្រពន្ធគាត់ ៖ ខ្ញុំគេឲ្យកិនស្រូវ កូននៅតូចគេឲ្យក្រង់ស្បូវឲ្យគេ ។

ដានី ៖ ចុះអត់មានគេឲ្យទៅលើកទំនប់ឬឲ្យទៅ...

នាម ៖ ខ្ញុំមិនដែលបានទៅលើកទំនប់អីទេ បើយាយគាត់បានទៅ ខ្ញុំកាន់តែគោ ។

ដានី ៖ ចុះខាងអ្នកគ្រប់គ្រងគេឈ្មោះអីខ្លះទៅអ៊ីដូចខាងសហករណ៍ ខាងឃុំខាងស្រុកណាស?

នាម : នេះពួកនេះនៅក្នុងនេះឯងក្តោបក្តាប់ណាស ប៉ុន្តែខាងនេះខាងនិរតីណាសតែខាងនោះអត់មានអ្នកនិរតីអត់មានទេ ។

ដានី : បាទ! ឈ្មោះអីខ្លះទៅអ៊ី?

នាម : កាលពួកពាយ័ព្យកាន់ មេឃុំឈ្មោះអីទេ ឈ្មោះ ផាង ។

ដានី : ឈ្មោះអីគេ?

នាម : ឈ្មោះ ផាង!

ដានី : ឈ្មោះ ផាង ហ្អី?

នាម : បាទ!

ដានី : ឃុំអីគេអាហ្នឹង?

នាម : ឃុំភ្នំលៀប ។

ដានី : ឃុំភ្នំលៀប?

នាម : បាទ!

ដានី : ចុះស្រុក គណៈស្រុក?

នាម : នៅនេះដូចមិនច្បាស់ព្រោះវាដូចនៅកណ្តាលវាលមិនដឹងអ្នកណាអ្នកណីទេ ខ្ញុំមិនច្បាស់ទេគណៈស្រុក ។

ដានី : អត់ច្បាស់ទេហ្អ?

នាម : អត់ច្បាស់ទេ ។

ដានី : ចុះកាលនោះមានមន្ទីរសន្តិសុខមានអីដែរអត់?

នាម : នៅ កាលនោះអត់ទាន់មានទេ ពាយ័ព្យនៅអត់ទាន់មានទេ ។

ដានី : ពួកពាយ័ព្យនៅអត់ទាន់មានទេ?

នាម : អត់ទាន់មានទេ ។

ដានី : ចុះអ៊ី ពួកនិរតីចូលមកពេលណា?

នាម : អត់ចាំទេ ។

ដានី : អ៊ីទៅនៅខាងត្រឡោកហ្នឹងបានរយៈប៉ុន្មានឆ្នាំបានពួកនិរតីមក?

នាម : ខ្ញុំអត់ចាំទេ ព្រោះកាលនោះខ្ញុំនៅនឹងត្រឡោកឆ្នាំ៧៧ ដល់ខ្ញុំជម្លៀសពីឆ្នាំ៧៧ហ្នឹងខ្ញុំទៅនៅចារអីណោះ ដល់ពួកនិរតីមកខ្ញុំអត់បាននៅនេះទេ ខ្ញុំនៅឯចារអីណោះ ។

ដានី : អីចឹងឆ្នាំ៧៧អ៊ីជម្លៀសទៅចារម៉ាសារទៀត?

នាម ៖ បាទ! បាទ!

ដានី ៖ ម៉េចបានគេជម្លៀសទៅ?

នាម ៖ នែ!បងខ្ញុំនៅខាងកំពង់ថ្កូវ គាត់នៅខាងណោះមើលតែគ្នាអត់ឃ្លានណាស់ បើនៅអីណោះអត់ឃ្លានណាស់ នៅអីណោះបបរតែម៉ាចានមិនដឹងនៅឯណាបើកន្លែងគាត់ធូរធាគ្រាន់ ក៏គាត់យកខ្ញុំទៅនៅអីណោះ ។

ដានី ៖ ហ្អូស!អីចឹងបងអឹមកយកទៅនៅចារវិញ?

នាម ៖ បាទ!

ដានី ៖ ចារហ្នឹងខាងណាវិញ?

នាម ៖ ឃុំភ្នំលៀប ហ្អូស! ឃុំទឹកជោរ ។

ដានី ៖ ឃុំទឹកជោរ?

នាម ៖ បាទ!

ដានី ៖ ក្នុងស្រុកអីគេវិញទឹកជោរហ្នឹង?

នាម ៖ ស្រុកព្រះនេត្រព្រះយើងហ្នឹង ។

ដានី ៖ ចុះបងអឹគាត់ធ្វើអីបានគាត់មកយកអឹ?

នាម ៖ គាត់ កាលនោះគាត់មិនធ្វើអីទេ តែគាត់អ្នកច្រូតស្បូវ គេដាក់ងារឲ្យគាត់ច្រូតស្បូវក៏គាត់ក្តាប់អ្នកច្រូតស្បូវហ្នឹងឯង ។

ដានី ៖ អីចឹងគាត់អាចមកយកអឹទៅ?

នាម ៖ បាទ!ទំនាក់ទំនងទៅក៏បាន មេភូមិថាយកមក បានយកទៅ ។

ដានី ៖ ឆ្នាំ៧៧ហ្អីអឹ?

នាម ៖ បាទ!

ដានី ៖ ខែប៉ុន្មានដែរអឹ?

នាម ៖ ខ្ញុំមិនចាំច្បាស់ដែរ ។

ដានី ៖ ខែប្រាំងឬខែវស្សា?

នាម ៖ ខែប្រាំង ។

ដានី ៖ ខែប្រាំងហ្អី?

នាម ៖ បាទ!

ដានី ៖ ខែប្រាំងហ្នឹងបានន័យថាខែច្រូតស្រូវហើយឬមិនទាន់ច្រូតទេ?

នាម ៖ ច្រូតហើយៗ ។

ដានី ៖ ខែហ្នឹងដូចថាខែកក្តិកខែរងារ ឬផុតអស់ហើយ?

នាម ៖ ផុតអស់ហើយ ។

ដានី ៖ ផុតរងារហើយ ។

ប្រពន្ធគាត់ ៖ ខែផល្គុន ។

ដានី ៖ ខែផល្គុនហ្អី? ចុះពេលអ៊ំទៅហ្នឹងខាងនិរតីគេអត់ទាន់មកទេ?

នាម ៖ នៅ!មិនទាន់មកទេ ។

ដានី ៖ តែអ៊ំទៅរយៈពេលប៉ុន្មានទៅបានពួកនិរតីមក?

នាម ៖ ខ្ញុំវាមិនចាំទេ ។

ដានី ៖ អាចថាប៉ុន្មានខែ?

នាម ៖ មិនដឹងថានិរតីវាចូលមកឆ្នាំណាទៀតនោះណាស វាមិនចាំទៀត ។

ដានី ៖ ចុះអ៊ំអីចឹងទៅម៉េចបានអ៊ំពេលទៅនៅចារអ៊ំមានដែលមកហ្នឹងទេ?

នាម ៖ នែ!ដល់យួនចូលមកបានៗមក ។

ដានី ៖ យ៉ាងម៉េចទៅអ៊ំពេលអ៊ំមក?

នាម ៖ យួនចូលមកបាញ់មកពីផ្លូវអីកើត មកពីភ្នំលៀបយើងនេះ ចេះតែបាញ់បណ្តើរៗមក ដល់មកពួកនរតីវារត់ ដល់បាញ់ដល់ តាប៉ុន ពួកនិរតីរត់ចេញមកវាលនេះ វាលភ្នំលៀបនេះ ចេញមកនេះមក ហើយខ្ញុំចេញមកភូមិវិញទៅ ។

ដានី ៖ ចូលទៅភូមិណា?

នាម ៖ ភូមិចារ កន្លែងដែលខ្ញុំនៅនេះ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

នាម ៖ ដល់ខ្ញុំនៅកន្លែងនោះទៅ ដល់ពួកលនិរតីចេញអស់ទៅក៏ប្រជាជននាំគ្នាព្រោងព្រាតថា ទៅភូមិទាំងអស់គ្នា ភូមិណាទៅភូមិនោះទៅបានៗខ្ញុំមក ។

ដានី ៖ ចុះអ៊ំមកដំបូងយ៉ាងម៉េចទៅ?

នាម ៖ មកដល់ជួបប៉ះពួកយួននៅតាមផ្លូវ តែគេមិនបានធ្វើអីទេ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

នាម ៖ មានអីមកតាមផ្លូវស្រួលទៅមកដល់ផ្ទះអត់មានអីទេ ។

ដានី ៖ ចុះអ៊ំមានប្រសាសន៍ថាអ៊ំបានឃើញកន្លែងធ្វើភ្នំត្រយ៉ូង ។

នាម ៖ បាទ!មកដល់ភ្នំត្រយ៉ូង ខ្ញុំមកផ្ទះមកក៏អត់មានឈើ ក្តារអី គេថាយកឈើក្រាល ឈើក្តាហ្នឹងឲ្យច្រើនៗ ខ្ញុំក៏ទៅទៅក៏ឃើញកន្លែងនោះឯង មានអ្នកងាប់ទៅ មានអ្នកទើបតែងាប់ក៏មាន មានអ្នកហើមក៏មាននៅតែកន្លែងនោះ កន្លែងសន្តិសុខនោះៗ

ដានី ៖ អ៊ំទៅឆ្នាំណា?

នាម ៖ ឆ្នាំ យួនចូលមកឆ្នាំណា?

ដានី ៖ ៧៩?

នាម ៖ បាទ!

ដានី ៖ ៧៩ ហ្នឹងខែណាអ៊ំដឹងទេ?

នាម ៖ កាលនោះខែ ជិតប្រូតរួចហើយៗ

ដានី ៖ ពេលដែលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញថ្ងៃ៧ មករា ឆ្នាំ១៩៧៩?

នាម ៖ បាទ!ពីនោះមកប្រហែលជាប៉ុន្មានថ្ងៃបានមកដល់នេះគេតាមមើល ស្មានតែប៉ុណ្ណឹងៗ

ដានី ៖ ពេលគេចូលបានប៉ុន្មានថ្ងៃបានអ៊ំបានទៅឃើញអាភ្នំទ្រយោងហ្នឹង?

នាម ៖ ចូលបានប្រហែលបួនប្រាំថ្ងៃៗ

ដានី ៖ បានបួនប្រាំថ្ងៃហ្អី?

នាម ៖ បាទ!

ដានី ៖ អ៊ំឃើញយ៉ាងម៉េច អ៊ំអាចរៀបរាប់កន្លែងឃើញទិដ្ឋភាពនៅកន្លែងភ្នំទ្រយោង?

នាម ៖ ទេ! ខ្ញុំទៅគ្រាន់តែខ្ញុំទៅក្រោយគេ គេរើយកអស់ណាសរោងណាស រោងដូចជាស័ង្កសីដូចជាក្តាឈើអីគេរើខ្វះអីខ្វះណាសដល់កន្លែងសន្តិសុខកន្លែងខ្នោះឃើញតែខ្នោះនោះៗ ខ្នោះនោះគេធ្វើឈើក្រុបពីរគេវាយចំកណ្តាលចេះទៅដាក់ជើងចេះទៅវាចូលអាឈើក្រុបលើមួយក្រោមមួយគេវាយកណ្តាលជាប់នៅហ្នឹងឯងៗ

ដានី ៖ អ៊ំឃើញមានអ្នកទៅជាប់ដែរអត់ពេលអ៊ំទៅឃើញ?

នាម ៖ ឃើញ តែស្លាប់អស់ហើយៗ

ដានី ៖ ស្លាប់អស់ហើយ?

នាម ៖ បាទ!

ដានី ៖ ស្លាប់ហ្នឹងទិដ្ឋភាពស្លាប់យ៉ាងម៉េចដែរ ស្លាប់ខ្លួនឯងឬស្លាប់ដោយគេសំលាប់ៗ

នាម ៖ ទេ មិនមែនគេសំលាប់ទេ ជាប់ខ្នោះទៅណាមិនរួចហ្នឹងស្លាប់ៗ

ដារ៉ា ៖ ពេលទៅដល់ឃើញសាកសពនៅហ្នឹងដែរ?

នាម ៖ បាទ!

ដារ៉ា ៖ នៅមានសាកសពនៅហ្នឹងទៀត?

នាម ៖ បាទមាន!

ដារ៉ា ៖ មានប៉ុន្មាននាក់ទៅ?

នាម ៖ ទេ ខ្ញុំឃើញតែពីរនាក់ទេ ។

ដានី ៖ ឃើញតែពីរទេ?

នាម ៖ បាទ!

ដានី ៖ អ៊ឹឃើញសាកសពហ្នឹងឃើញស្ថានភាពម៉េចដែរ?

នាម ៖ ស្គម ប្រហែលទើបតែស្លាប់ថ្មីៗ ស្គម ហើយអាណាយូរក៏ហើមតែប្អូនប្រាំប្រាំមួយប្រាំបិល ថ្ងៃវាហើមហើយ ។

ដានី ៖ ស្រីឬប្រុសសាកសពហ្នឹង?

នាម ៖ ប្រុស ។

ដានី ៖ អាយុប្រហែលស្របាលប៉ុន្មាន?

នាម ៖ មិនដឹងថាអាយុប៉ុណ្ណាដល់វាស្គមស្គាំងទៅរកស្មានមិនត្រូវ ។

ដារ៉ា ៖ អីចឹងមានន័យថាក្នុងកំឡុងពេលម៉ារបបខ្មែរក្រហមហ្នឹងអ៊ឹអត់បានដឹងទេ?

នាម ៖ អត់បានដឹង ។

ដារ៉ា ៖ អត់ដែលព្ញឈ្មោះទេចឹង?

នាម ៖ បាទ អត់ដែលបានឃើញទេនៅសម័យនោះណាស ទាល់តែចូលមក យួនចូលមកបាន ឃើញព្រោះខ្ញុំមិនបាននៅកន្លែងនេះ ។

ដារ៉ា ៖ ពីភ្នំស្រយ៉ូងមកកន្លែងឃុំហ្នឹងប៉ុន្មានគីឡូ ។

នាម ៖ ទេ!មិនឆ្ងាយទេប្រហែលជាពីរគីឡូ ។

ដារ៉ា ៖ ប្រហែលពីរគីឡូ?

នាម ៖ បាទ! ប្រហែលជាពីរគីឡូ ។

ដារ៉ា ៖ អីចឹងនៅក្នុងទឹកដីភ្នំលៀបហ្នឹងឯងចឹង?

នាម ៖ បាទ!ព្រោះនៅក្នុងទឹកដីភ្នំលៀបនេះគ្រាន់តែនៅក្នុងភូមិជួបជុំគ្នាគេមានបីភូមិឃុំភ្នំលៀបនេះ ទៅឆ្ងាយវាមានដែរក៏ប៉ុន្តែវានៅជាប់នឹងជាយឃុំ ព្រំដែនជាប់នឹងជាយឃុំតែម្តង ។ បើទៅ តាមភូមិឆ្ងាយៗ ឃុំភ្នំលៀបដូចគ្នាតែវាឆ្ងាយពីគ្នា ។

ដានី ៖ ចុះកាលអ៊ំទៅឃើញសាកសពហ្នឹងអ៊ំមានឃើញអីទៀតក្រៅពីសាកសពហ្នឹងទេ?

នាម ៖ ទេ! មិនមានអីទេមាន តែឃើញតែរោងបាក់បែកគេរើរ ព្រោះខ្ញុំទៅក្រោយគេ ហើយគេនៅ ជិតនេះគេឆាប់បានរើរ ។

ដានី ៖ គេរើរយកអីគេ?

នាម ៖ រើយកឈើយកស័ង្កសី សំភារៈដូចជាចប ដូចជាកាំបិតអី ។

ដានី ៖ តែអ៊ំទៅអត់មានសំភារៈអីទេ?

នាម ៖ អត់ទេ ។

ដានី ៖ ចុះបើ អ៊ំសន្និដ្ឋានមើលអាកន្លែងមន្ទីរសន្តិសុខគេហ្នឹងប្រហែលជាទំហំប៉ុណ្ណាទៅទទឹងបណ្តោយ?

នាម ៖ ហួស!ថាមិនត្រូវទេ រកថាមិនត្រូវទេ ព្រោះគេរើអស់ហើយអីចឹងមិនដឹងប៉ុណ្ណាទេ បើទៅឃើញអាគេមិនទាន់រើអាហ្នឹងអាចប៉ាន់ស្មានកើត ដល់គេរើអីណាអីណីអស់ទៅហើយចោះ ។

ដានី ៖ ចុះកាលអ៊ំនៅចារ កាលនោះអ៊ំមានដែលឮមន្ទីរសន្តិសុខហ្នឹងដែរអត់?

នាម ៖ ទេ!ខ្ញុំមិនដែលដឹងទេ ។

ដានី ៖ អត់ដែលដឹងអត់ដែលឮទេ?

នាម ៖ បាទ!អត់ដែលឮទេទើបតែចូលភូមិមកបានគេថាបានគេប្រាប់ ។

ដានី ៖ ចុះអ៊ំកាលនៅចារហ្នឹងធ្វើអីគេទៅ?

នាម ៖ ខ្ញុំនៅតែភ្ជួររាស់ទេ កាន់គោរហូត ។

ដានី ៖ កាន់គោរហូត?

នាម ៖ បាទ!

ដានី ៖ ប៉ុន្តែកាលនោះអ៊ំមានដែលឮថាពួកនិរតីចូលមកដែលឮឈ្មោះថាពួកនិរតីគេចូលមកគ្រប់គ្រងថ្នាក់ស្រុកថ្នាក់ឃុំនៅមន្ទីរសន្តិសុខអីមានដែលឮទេ?

នាម ៖ អត់ដែលឃើញមានទេ មិនដែលមានឮទេ ។

ដានី ៖ ចុះអ៊ំអត់ស្គាល់គណស្រុកពីណាទេកាលពីនិរតីចូលមក?

នាម ៖ កាលនិរតីចូលមក មកក៏ឮគេប្រាប់ ប៉ុន្តែដែលខ្ញុំមកឃើញ កាលនោះខ្ញុំមកម្តង ខ្ញុំមកម្តងនៅភ្នំលៀបនោះកាលសម័យបីឆ្នាំណាស មកឃើញ យាយថែម ម្តងប៉ុណ្ណោះឯង គាត់កាន់អត់ស្គាល់ទេ អត់ឃើញទេឃើញតែ យាយថែម ប៉ុណ្ណោះឯង ។

ដានី ៖ កាលនោះអ៊ំឃើញគាត់នៅកន្លែងណា?

នាម ៖ គាត់នៅអង្គុយលេងនៅផ្ទះគាត់ ។

ដានី ៖ ផ្ទះគាត់នៅឯណា?

នាម ៖ ផ្ទះគាត់នៅកន្លែងអាផ្ទះធំនៅជាប់នឹងមន្ទីរពេទ្យ ។

ដានី ៖ មន្ទីរពេទ្យ មណ្ឌលសុខភាពឃុំហ្នឹងហ្អី?

នាម ៖ បាទ!នោះឯងផ្ទះដែលគាត់នៅកាលសម័យនោះ ។

ដារ៉ា ៖ ផ្ទះនោះឥឡូវមានគេនៅ?

នាម ៖ បាទ!ផ្ទះនោះនៅ ម្ចាស់គេនៅ ។

ដារ៉ា ៖ ម្ចាស់គេនៅហើយហ្ន?

នាម ៖ បាទ!ម្ចាស់គេពីសង្គមចាស់ណាស គេចប់គេមកនៅ ។

ដារ៉ា ៖ អីចឹងបានន័យថាអ៊ំបានឃើញ យាយថែម កាលជំនាន់ប៉ុន្មានឆ្នាំ?

នាម ៖ បាទ!បានម្តង ។

ដារ៉ា ៖ កាលនោះបានឃើញរូបរាងគាត់អីយ៉ាងម៉េចដែរ?

នាម ៖ តែយើងខ្លាចគេចង់ស្លាប់មិនបានឃើញបានសម្លឹងគេឯណា ។ នៅសម័យនោះខ្លាចណាស់ មិនហ៊ានមើលមុខគេឲ្យច្បាស់លាស់ទេ ។

ដារ៉ា ៖ អីចឹងអ៊ំដឹងថា យាយថែម ហ្នឹងធ្វើស្អីអីចឹង?

នាម ៖ អត់មានធ្វើអីទេ គាត់អង្គុយលើផ្ទះ ។

ដារ៉ា ៖ អត់ទេចង់និយាយថា ឋានៈ តួនាទីគាត់?

នាម ៖ អូ! ឋានៈគាត់នោះ គាត់គណៈស្រុក ។

ដារ៉ា ៖ គណៈស្រុក?

នាម ៖ បាទ!

ដារ៉ា ៖ អ៊ំដឹងអីចឹងដែរ?

នាម ៖ បាទ! ដឹង គណៈស្រុក ។

ដារ៉ា ៖ គណៈស្រុក?

នាម ៖ បាទ! ប៉ុណ្ណោះឯង ។

ដារ៉ា ៖ អ៊ំឃើញគាត់អីចឹង ដូចថាមានការភិតភ័យអីទេ?

នាម ៖ ការភិតភ័យដែរ ព្រោះមិនដែលមកម្តាក់ម្តងផង ។

ដារ៉ា ៖ ពីផ្ទះកន្លែង យាយថែម នៅទៅកន្លែងមន្ទីរសន្តិសុខភ្នំទ្រយោងហ្នឹងប៉ុន្មានគីឡូ?

នាម ៖ នេះគិតត្រឹមទ្រយោងជិតគ្នានេះ ផ្ទះនៅណោះ ឆ្ងាយគ្រាន់ ខ្ញុំថាប្រហែលពីរគីឡូ ។

ដារ៉ា ៖ ពីរគីឡូដីទេ?

នាម ៖ បាទ!

ដារ៉ា ៖ អីចឹង?

នាម ៖ បាទ!

ដានី ៖ ចុះអ៊ីកាលហ្នឹងម៉េចអ៊ីមកកន្លែងហ្នឹង បើអ៊ីនៅចាណោះ?

នាម ៖ អីចេះ កាលណោះគេឲ្យខ្ញុំមកដកសំណាបនៅខាងគោកកី ។

ដានី ៖ ខាងគោកកី?

ដារ៉ា ៖ គោកកីអីចឹង?

នាម ៖ បាទ! នៅភូមិគោកកី នៅទៅជើងដែលប្អូនឯងទៅអម្បាញ់មិញណា នៅខាងជើងនោះ ។

ដានី ៖ បាទ! ដល់ពេលកាលហ្នឹង អ៊ីធ្វើដំណើរយ៉ាងម៉េចកាលហ្នឹងដូចថាយើង?

នាម ៖ មកឈប់ ។

ដានី ៖ ជិះអីមកកាលហ្នឹង?

នាម ៖ រទេះ ។

ដានី ៖ បររទេះ?

នាម ៖ បាទ!

ដានី ៖ មកឈប់កន្លែង?

ដារ៉ា ៖ ផ្ទះយាយ ថែម ហ្នឹង?

នាម ៖ ទេ! មិនបានឈប់ទេ មកនោះគេឲ្យខ្ញុំមកប្រជុំមួងអីចេះ ឃើញច្បាស់ណាស់ណា យាយ ថែម ។

ដារ៉ា ៖ មកប្រជុំ?

នាម ៖ បាទ! ដល់ក្រោយមក ខ្ញុំបោះពួយអីចេះទៅ បររទេះទៅដកសំណាប ។

ដារ៉ា ៖ មកប្រជុំហ្នឹង មកប្រជុំជាមួយ យាយ ថែម ម៉ង?

នាម ៖ ទេ មកប្រជុំផ្សេងទេ ។ ណោះអត់មាន យាយ ថែម និយាយពីរឿងការងារនេះទេ អត់មានទេ ។

ដារ៉ា ៖ តែគ្រាន់តែឃើញគាត់?

នាម ៖ បាទ! គ្រាន់តែឃើញ ។

ដារ៉ា :	ឃើញពីចម្ងាយណា?

នាម :	ឃើញឆ្ងាយនោះឯង គាត់នៅលើផ្ទះ ខ្ញុំនៅតែដី ។

ដានី :	ប្រហែលចម្ងាយប៉ុន្មានម៉ែត្រដែលអ៊ំឃើញគាត់នៅលើផ្ទះមកកន្លែងអ៊ំនៅដីហ្នឹង ប្រហែលប៉ុន្មាន?

នាម :	ប្រហែលពី៥ម៉ែត្រ ៦ម៉ែត្រនោះ ។

ដានី :	៦ម៉ែត្រ ជិតដែរអ៊ីចឹង?

នាម :	បាទ!

ដានី :	នៅជិតដែរ អ៊ំអាចស្រមៃឃើញរូបគាត់យ៉ាងម៉េច រាងរូវគាត់ ពណ៌សម្បុរគាត់អ៊ី?

នាម :	ទេមិនចាំទេ ។

ដារ៉ា :	អ៊ីចឹងមកដំបូង បើសិនជាឃើញ យាយ ចែម អ៊ីចឹង ម៉េចអ៊ំហ៊ានសន្មតថាហ្នឹង យាយចែម?

នាម :	មានគេប្រាប់ ។

ដារ៉ា :	អ្នកណាគេប្រាប់អ៊ំកាលហ្នឹង?

នាម :	កាលណោះ ពួកយោធា ប៉ុន្តែមិនដែលស្គាល់នរណាទេ យោធាហ្នឹងមិនស្គាល់ទេ ។

ដារ៉ា :	ហេតុអ៊ីបានគេប្រាប់អ៊ំថាហ្នឹង យាយចែម គេប្រាប់?

នាម :	គេថា យាយ ចែម ខ្ញុំមិនបានជាសួរគេថាហ្នឹង យាយ ចែមទេ ប៉ុន្តែគេប្រាប់ថានៅលើផ្ទះៗ អ៊ីចឹងបានខ្ញុំឃើញម្តង ។

ដារ៉ា :	ឃើញគាត់ម៉ង?

នាម :	បាទ! បានឃើញម្តង ។

ដានី :	ចុះអ៊ំកាលហ្នឹងមានឮដំណឹងថា យាយចែម គាត់ម៉េចដែរ?

នាម :	ទេមិនមានទេ រឿងសកម្មភាពរបស់គាត់ខ្ញុំ សកម្មភាពរបស់គាត់ខ្ញុំមិនដឹងទេ ។

ដានី :	ដែលឮថាគាត់ ដូចថា យាយចែម គាត់មនុស្សយ៉ាងម៉េច គាត់គ្រប់គ្រងអ៊ីយ៉ាងម៉េចមានដែលឮទេ?

នាម :	អត់ដែលមានឮទេ ។

ដានី :	មិនដែលឮទេ?

នាម :	បាទ!

ដានី ៖ ចុះអ៊ី ដល់ពេលអ៊ីផ្ទាល់អ៊ីចឹងដូចថាធ្លាប់ឆ្លងកាត់តាំងពីមុនសម័យពួកនិរតីមក មិនពួក ពាយព្យគេអ្នកកាន់កាប់អ៊ីចឹងអី?

នាម ៖ បាទៗ!

ដានី ៖ ចុះកាលពេលពួកពាយ័ព្យ ពេលពួកនិរតីចូលមកហ្នឹង ជនាន់ យាយ ចែម ចូលមកខុសគ្នា យ៉ាងម៉េចទៅ?

នាម ៖ បាទ! កាលដែលថ្មីៗចូលមក បើខ្ញុំនៅខាងណោះណា ខ្ញុំមិនមែននៅនេះទេ កាលសម័យ និរតីចូលមក ខ្ញុំនៅខាងណោះ នៅចារ នៅខាងចារឯណោះ កាលវាចូលមក វាឲ្យស៊ី ធម្មតា ដល់យូរៗទៅកាន់តែតឹងឡើងៗ របបដូចតែគ្នា ដូចតែនៅកន្លែងនេះដែរ ។

ដានី ៖ បាទ! ដល់ពេលបបរដូចគ្នាហ្នឹង បានន័យថារឹតបន្តឹងទៅៗ ពួកពាយព្យរឹត?

នាម ៖ អត់ទេ ពួកហ្នឹងកាលណោះពួកពាយព្យអត់មានៗសិទ្ធិអីចេះទេ នៅលើគេទាំងអស់ ។

ដានី ៖ ពីណា?

នាម ៖ នៅលើនិរតី ។

ដានី ៖ និរតី?

នាម ៖ បាទ!

ដានី ៖ ចុះអ៊ីអម្បាញ់មិញថាស្គាល់ យាយ ចែម គាត់គណៈស្រុក?

នាម ៖ បាទ!

ដានី ៖ ចុះពីណាប្រធានបន្តបន្ទាប់ពីគាត់ទៀត?

នាម ៖ ខ្ញុំអត់ដឹងទេ ។

ដានី ៖ ចុះមួយមិញដែលអ៊ីថាឈ្មោះអីមិញនោះ?

នាម ៖ កាន់?

ដានី ៖ កាន់?

នាម ៖ គាត់ឃុំ គ្រប់គ្រងឃុំនេះឯង ឃុំភ្នំលៀប ។

ដានី ៖ ឃុំភ្នំលៀប?

នាម ៖ បាទ! គ្រាន់តែឮទេ អត់ឃើញមុខទេ មិនដែលបានឃើញមុខទេ មិនដែលបានឃើញរូប ទេ ។

ដានី ៖ ចុះអ៊ី ដែលអ៊ីថាឃើញយាយ ចែម ហ្នឹងមកប្រជុំនៅឆ្នាំណាទៅ?

នាម ៖ ប្រហែលជា ៧៩ហើយ ប៉ុន្តែប្រហែលជាដើមឆ្នាំ ។

ដានី ៖ ៧៩?

នាម ៖ បាទ! ដល់ខ្ញុំទៅវិញ ទៅដល់ប្រធានសហករណ៍នៅណោះគេថា នៅតែដល់ថ្ងៃទៀតឯង ត្រូវគេវៃចោល ថាអីចេះប្រាប់ខ្ញុំណា ។

ដានី ៖ ម៉េចបានគេថាអីចឹង?

នាម ៖ គេថា គេខឹងឲ្យប្រជាជនទៅប្រជុំ ខ្ញុំនេះប្រជាជន មិនមានធ្វើការធ្វើងារគេទេណា កាន់តែគោ ក្របីតែស្រែ ដល់ប្រធានសហករណ៍នោះគេឃើញ គេហៅខ្ញុំមកប្រជុំ ដល់ទៅវិញ ពួកនិរតីគេខឹង គេថានៅតែ១០ថ្ងៃទៀតវៃចោលណា ប៉ុន្តែយួនឆាប់ចូលមកណា ខ្ញុំថាប្រហែលជាដើមឆ្នាំ៧៩ ។

ដារ៉ា ៖ អាចចុង៧៨ដែរអី?

នាម ៖ បាទៗ! ដើមឆ្នាំ៧៩ ចូលមកបើសិននៅដល់កន្លះខែគេវៃខ្ញុំចោលបាត់ហើយ ចុះអានេះយួនចូលឆាប់មកបានខ្ញុំរួចខ្លួន ។

ដានី ៖ ចុះអ៊ីខាងមន្ទីរសន្តិសុខភ្នំទ្រយោងហ្នឹង អ៊ីដឹងថាពីណាគេអ្នកណាគេធ្វើប្រធាននៅហ្នឹង?

នាម ៖ អត់ដឹងទេ ។

ដារ៉ា ៖ ចុះក្រោយមក អ៊ីនៅខាងក្រោយមកទៀតមានអ្នកស្រុកអ្នកភូមិអីនិយាយតៗគ្នាអី អ៊ីមានបានឮទេ?

នាម ៖ ទេ មិនដែលបានដឹងទេ ខ្ញុំមិនដែលបានសួរអាចឹងៗសោះ ។

ដារ៉ា :

តែបើសិនជាចង់ដឹងច្បាស់អំពីមន្ទីរសន្តិសុខទ្រយោងហ្នឹងនៅក្នុងភូមិហ្នឹងមានអ្នកណាដឹងច្បាស់ ទេ?

នាម ៖ ទេ ខ្ញុំមិនដឹងទេ បានខាងណោះ...មិនដែលបានពិនិត្យមើល មិនដែលគិតគូគេខាងណាទេ មិនដែលបាន... ។

ដានី ៖ តែអ៊ីពួកខ្ញុំដូចអត់មានសំណួរអីត្រូវសួរនាំអ៊ីទៀតទេ អីចឹងអ៊ីមានអីចង់បន្ថែមនូវអីដែលពួកខ្ញុំអត់ទាន់បានសួរនាំអ៊ីទេ?

នាម ៖ ទេមិនដឹងបន្ថែមថាម៉េច ។

ដារ៉ា ៖ ដូចថាអ៊ីបានឆ្លើយពីមុនមកអស់ ហើយថាក្រោយមកទើបអ៊ីបានដូចថានឹកឃើញរឿងអីថ្មីមួយទៀតអីចឹងអ៊ី?

នាម ៖ ទេអត់មាន ។

ដារ៉ា ៖ មានអីជួយបន្ថែមអីចឹងណា អត់មានទេ?

នាម ៖ អត់មានទេ ។

ដារ៉ា ៖ អត់មានទេ អីចឹងពួកខ្ញុំអរគុណអ៊ំច្រើនហើយបានផ្តល់ព័ត៌មាន ។

នាម ៖ បាទ!

ដានី ៖ អរគុណអ៊ំច្រើនហើយ ។

«ចប់»